**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតគណៈកម្មការអចិន្ត្រៃយ៍គ្រប់គ្រងសារមន្ទីរខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរអប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្ដីពី ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរអប្សរា ឱ្យស្របជាមួយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យ លេខ នស/ រកត /១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្ដីពីការកែសម្រួល មាត្រា៤ និង មាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា

- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលមាត្រា៦ និង មាត្រា១៤ នៃអនុក្រឹត្យលេខ ១៥.អនក្រ .បក. ចុះ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា។
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរអប្សរា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មការអចិន្ត្រៃយ៍គ្រប់គ្រងសារមន្ទីរនៅខេត្តសៀមរាបដែលរួមមាន :

១. សារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ
២. សារមន្ទីរវត្ថុបុរាណ សៀមរាប-អង្គរ
៣. សារមន្ទីរអភិរក្សដ្ឋានអង្គរ ។

**មាត្រា ២.-**

គណៈកម្មការអចិន្ត្រៃយ៍គ្រប់គ្រងសារមន្ទីរ មានភារកិច្ចត្រួតពិនិត្យសម្ភារៈ បរិក្ខារ និងវត្ថុបុរាណ ព្រមទាំងកម្មវិធីការងារនៃសារមន្ទីរទាំងបី ។

គណៈកម្មការត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះមុខច្បាប់ជាធរមាន រួមទាំងផ្នែកព្រហ្មទណ្ឌផងដែរ អំពីកិច្ចការងារអភិរក្ស ការថែរក្សា ការពារសមុច្ច័យ និងសុវត្ថិភាពវត្ថុបុរាណ ដែលតម្កល់នៅក្នុងសារមន្ទីរ ។

គណៈកម្មការត្រូវធ្វើរបាយការណ៍ជាប្រចាំ ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីស្ថានភាពសារមន្ទីរ និងស្ថានភាពសមុច្ច័យវត្ថុបុរាណ។

**មាត្រា ៣.-**

គណៈកម្មការមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- | ឯកឧត្តមអគ្គនាយកអាជ្ញាធរអប្សរា | ប្រធាន |
| ២- | ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣- | អភិបាលរងខេត្តសៀមរាបមួយរូប | អនុប្រធាន |
| ៤- | ស្នងការនគរបាលខេត្តសៀមរាប | សមាជិក |
| ៥- | ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការនៃអាជ្ញាធរអប្សរា | សមាជិក |
| ៦- | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៧- | ប្រធាននគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប | សមាជិក |
| ៨- | ប្រធាននគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប | សមាជិក |
| ៩- | អភិបាលស្រុកសៀមរាប | សមាជិក |
| ១០- | មេឃុំស្លក្រាម និងមេឃុំស្វាយដង្គំ | សមាជិក |

១១- តំណាងអង្គការយូណេស្កូ ដែលជាអ្នកជំនាញផ្នែកវប្បធម៌ សមាជិក
១២- មន្ត្រីអគ្គនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
១៣- មន្ត្រីអាជ្ញាធរអប្សរា ជាអ្នកសម្របសម្រួល និងជា សមាជិក។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិអប្សរា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អភិបាលខេត្តសៀមរាប រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូន សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីសូមហត្ថលេខា

ប្រធានអាជ្ញាធរអប្សរា

**សុខ អាន**

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ